ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ០២...

ភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥

**សេចក្តីណែនាំរួម**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ប្រធានតុលាការកំពូល**

**សូមជំរាបមក**

- **លោកប្រធាន អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត-ក្រុង**
- **លោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អមតុលាការខេត្ត-ក្រុង**

**កម្មវត្ថុ** : សេចក្តីណែនាំអំពីការអនុវត្តមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

កន្លងមកក្រសួងយុត្តិធម៌ និងតុលាការកំពូលបានពិនិត្យឃើញថា ការអនុវត្តមាត្រា ៤៦ ស្តីពីអំពើរំលោភលើសេចក្តីទុកចិត្ត នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ មិនទាន់បានឯកភាពគ្នានៅឡើយ នៅតាមតុលាការទូទាំងប្រទេស ។ ម្យ៉ាងវិញទៀតចំពោះការបែងចែកវិវាទរដ្ឋប្បវេណី ដែលជាការមិនបំពេញកាតព្វកិច្ចកើតចេញពីកិច្ចសន្យា និងអំពើដែលត្រូវផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្ត កំពុងស្ថិតនៅជាបញ្ហាដែលទាមទារឱ្យមានការដោះស្រាយផងដែរ ។

ការរំលោភសេចក្តីទុកចិត្ត គឺជាអំពើកែបន្លំ ឬបំបាត់ រំលោភកាន់កាប់មួយចំណែក ឬទាំងអស់នូវទ្រព្យសម្បត្តិអ្នកដទៃ ដែលគេបានប្រគល់អោយខ្លួនអាស្រ័យដោយការជឿទុកចិត្តរបស់ម្ចាស់ទ្រព្យ ឬអ្នកកាន់កាប់ទ្រព្យដែលសង្ឃឹមថា ទទួលបានមកវិញនូវទ្រព្យសម្បត្តិ ឬលទ្ធផលនៃការងារណាមួយពីអ្នកទទួលនូវទ្រព្យទាំងនោះ ។

ដើម្បីជាមូលដ្ឋានសំរាប់ការចោទប្រកាន់ និងការវិនិច្ឆ័យរឿងក្តី និងការបែងចែករវាងវិវាទរដ្ឋប្បវេណី និងបទល្មើសរំលោភលើសេចក្តីទុកចិត្ត ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមធ្វើការណែនាំដល់តុលាការ និងអយ្យការខេត្ត-ក្រុង យកចិត្តទុកដាក់ ពិចារណាលើលក្ខណៈគតិយុត្ត ដែលបានបញ្ញត្តិក្នុងមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចរៀបរាប់ខាងក្រោម ។

**ធាតុផ្សំនៃបទល្មើសរំលោភលើសេចក្តីទុកចិត្តមាន:**

១. មានច្បាប់ចែង ឧទាហរណ៍ មាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

Downloaded from http://www.khmerlaws.com

២. ជនល្មើសមានចេតនាទុច្ចរិត កែបន្លំ ឬបំបាត់ទ្រព្យដែលខ្លួនបានទទួល ពោលគឺការមិនបានប្រគល់ ឬបង្ហាញនូវទ្រព្យ ឬលទ្ធផលនៃការងារកើតឡើងដោយឆន្ទៈមិនប្រគល់ពិតប្រាកដ ដែលពុំមែនកើតឡើងដោយឧបសគ្គសក្យានុម័តនោះឡើយ ហើយត្រូវមានអំពើកែបន្លំ ឬបំបាត់ទ្រព្យសម្បត្តិប្រព្រឹត្តដោយអ្នកទទួលបាននូវទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ដែលស្តែងឡើងក្រោមរូបភាពជាការមិនប្រគល់ ឬប្រគល់ តែបានបន្លំបរិមាណ ឬគុណភាពនៃទ្រព្យសម្បត្តិទាំងនោះ ។

៣. សំភារៈ ឬមុខសញ្ញា នៃបទរំលោភលើសេចក្តីទុកចិត្តរួមមាន ៖

ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ គ្រប់ឯកសារដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រគល់អោយជនខ្លួន ក្នុងលក្ខណៈជាការជួល ការតំកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសំរាប់ប្រើប្រាស់ ឬជាមុខការមានកំណត់ ដែលម្ចាស់ទ្រព្យបានផ្ទុកផ្តាក់ទ្រព្យរបស់ខ្លួនអោយទៅភាគីម្ខាង ហើយភាគីម្ខាងបានទទួលទ្រព្យនេះដោយស្របច្បាប់ តាមរយៈកិច្ចសន្យាប្រាំមួយប្រភេទគឺៈ កិច្ចសន្យាជួល កិច្ចសន្យាផ្ញើទុក កិច្ចសន្យាបញ្ចាំ កិច្ចសន្យាអោយខ្ចីប្រើ កិច្ចសន្យាអាណត្តិ និងកិច្ចសន្យាការងាររវាងកម្មករ និងនិយោជិត ឬ មិនមែនរវាងនិយោជក និងកម្មករ. និយោជិត ។

៤. មានការអន្តរាយ ពោលគឺខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ ដែលបានប្រគល់នូវទ្រព្យទាំងនោះ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមរំលឹក និងសូមឱ្យលោកចៅក្រម ពិចារណាឱ្យបានល្អិតល្អន់ចំពោះការមិនបានបំពេញករណីយកិច្ច ដែលកើតចេញពីកិច្ចសន្យារដ្ឋប្បវេណីផ្សេងទៀត ក្រៅពីប្រភេទកិច្ចសន្យាទាំង ៦ ដែលបានលើកឡើងខាងលើ ដូចជាកិច្ចសន្យាលក់-ទិញ កិច្ចសន្យាខ្ចីបរិភោគ ដូចជាកិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាឱ្យ ឬប្រទានកម្ម ដែលភ្ជាប់ករណីយកិច្ច.........ទោះបីដោយមូលហេតុណាក៏ដោយ ដែលអ្នកទទួលបាននូវទ្រព្យ មិនបានបំពេញករណីយកិច្ចប្រគល់ឱ្យទៅអ្នកប្រគល់វិញ នូវទ្រព្យនោះមិនមែនជាអំពើកែបន្លំ ឬបំបាត់ ដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្តនោះឡើយ ។

ការធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិតាមរយៈអំពើណាមួយ ដែលមិនរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្ត អាចជាបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើអំពើនោះត្រូវបានចែងក្នុងច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល នឹងមានវិធានការតាមផ្លូវច្បាប់ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់

Downloaded from http://www.khmerlaws.com

ក្រសួងយុត្តិធម៌ និងតុលាការកំពូលសង្ឃឹមថា អស់លោកចៅក្រម នឹងយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវនូវបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដើម្បីការពារសិទ្ធិរបស់ ពលរដ្ឋ ជួយរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងបង្កើនការជឿជាក់របស់ពលរដ្ឋ និងអ្នកវិនិយោគលើ ប្រព័ន្ធតុលាការ និងច្បាប់របស់កម្ពុជា ។

ប្រធានតុលាការកំពូល

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ វង្សវឌ្ឍនៈ

<u>ចម្លងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និង មហាអយ្យការ
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com

Downloaded from http://www.khmerlaws.com